**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 08-Feb-2013, 15:27
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សេចក្ដីជំទាស់នៅលើឯកសារពាក់ព័ន្ធនឹងការជម្លៀសប្រជាជន និងទីតាំងទួលពោធិ៍ជ្រៃ**

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ូរ ឧត្ដរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ូច ស្រីផាត់

កញ្ញា ជុន សុធារី

លោក Pierre TOUCHE

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. យោងតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង") អង្គជំនុំជម្រះសាលាដំបូង អាចប្រកាសបដិសេធធាតុនៃភ័ស្តុតាងណាមួយ បើយល់ឃើញថាវា៖ "ក) មិនជាប់ពាក់ព័ន្ធ ឬមានលក្ខណៈច្រំដែល ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ) មិនសមស្រប សម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង ឃ) ច្បាប់មិនអនុញ្ញាត ឬ ង) មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍"។

២. បទបញ្ញត្តិនេះរឹតត្បិតវិធាន ៨៧(១) ដែលចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភ័ស្តុតាងទាំងអស់ត្រូវតែទទួលយក"។ ដូច្នេះ ក្រៅពីត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពអាចជឿទុកចិត្តបាន និងយថាភាព ដើម្បីអាចទទួលយកបាន ភ័ស្តុតាងត្រូវមានភាពពាក់ព័ន្ធ មិនច្រំដែល អាចរកបានក្នុងរយៈពេលសមស្របណាមួយ សមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង ទទួលបានដោយស្របច្បាប់ និងមិនមានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬមានប្រយោជន៍។ លោក ខៀវ សំផន លើកឡើងនូវការជំទាស់ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យទាំងនេះ។

៣. សារណានេះពាក់ព័ន្ធតែនឹងឯកសារ ដែលជាកម្មវត្ថុនៃកិច្ចពិភាក្សាដេញដោល ក្នុងអំឡុងសវនាការថ្ងៃទី ២១ និងថ្ងៃទី ២២ ខែមករា ឆ្នាំ ២០១៣ ដែលលោក ខៀវ សំផន មិនអាចចូលរួមបាន ដោយហេតុផលសុខភាព។ នៅក្នុងអនុស្សរណៈរៀបចំកាលវិភាគសវនាការ អង្គជំនុំជម្រះបានបញ្ជាក់ថា ភាគីនឹងត្រូវផ្តល់ឱកាសឲ្យលើកទឡ្ហីករណ៍ជំទាស់ទៅលើឯកសារចំនួន ៤៨ ដែលត្រូវបានសហព្រះរាជអាជ្ញាកំណត់ថាជាឯកសារមិនទាន់បានលើកយកមកពិភាក្សាដេញដោល (E223/2/1.1) និងឯកសារចំនួន ៩៤ ដែលសហព្រះរាជអាជ្ញាមានបំណង់បង្ហាញ ពាក់ព័ន្ធនឹងទីតាំងទួលពោធិ៍ជ្រៃ និងការជម្លៀសប្រជាជន ដំណាក់កាលទីមួយ និងដំណាក់កាលទីពីរ (មាននៅក្នុងឧបសម្ព័ន្ធរបស់សហព្រះរាជអាជ្ញា E223/2/1.2, E223/2/1.3 និង E223/2/1.4)[1]។ ដើម្បីឲ្យមានភាពច្បាស់លាស់

[1] អនុស្សរណៈស្តីពីកាលវិភាគដែលបានកែសម្រួលថ្មី សម្រាប់សវនាការលើឯកសារនាពេលខាងមុខ (ចាប់ផ្តើមពីថ្ងៃ ច័ន្ទ ទី ២១ ខែ មករា ឆ្នាំ ២០១៣) ឯកសារ E223/3 កថាខណ្ឌ ៣។

លោក ខៀវ សំផន ភ្ជាប់ទៅនឹងសារណានេះនូវឧបសម្ព័ន្ធទាំងនេះ ដែលត្រូវបានរៀបជាតារាង ដោយបញ្ចូលនូវខ្ទង់បន្ថែមសម្រាប់ការកត់សម្គាល់របស់ខ្លួន។

៤. ក្នុងពេលសវនាការ មេធាវីការពារក្តីលោក ខៀវ សំផន បានរកឃើញឯកសារចំនួន ៥៦ បន្ថែម ដែលមិនទាន់បានពិភាក្សាដេញដោល ហើយបានផ្តល់បញ្ជីឯកសារជូនភាគី។ សហព្រះរាជអាជ្ញា បានអះអាងថា ឯកសារភាគច្រើនត្រូវបានពិភាក្សាដេញដោលរួចមកហើយ។ លោក ខៀវ សំផន នឹងមិនភ្ជាប់ជាឧបសម្ព័ន្ធនូវតារាងឯកសារទាំង ៥៦ នេះទេ ប៉ុន្តែ នឹងបញ្ជាក់ជូននៅផ្នែកទីពីរនៃ សារណានេះ នូវឯកសារដែលខ្លួនមានបំណងចង់ជំទាស់។

៥. លោក ខៀវ សំផន សូមរំឭកផងដែរថា ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា មិនមានការ ពិភាក្សាដេញដោលលើឯកសារថ្មីទាំងអស់ ដែលសហព្រះរាជអាជ្ញាចង់ដាក់បង្ហាញនោះទេ។ ដូច្នេះ នៅសល់ឯកសារប្រហែល ៥០០ ទៀត ដែលត្រូវពិភាក្សាដេញដោល (E190.1 និង E190/2.1)។ មេធាវីការពារក្តីស្នើសុំជាថ្មីម្តងទៀត[2] ឲ្យអង្គជំនុំជម្រះមេត្តាអនុញ្ញាតឲ្យខ្លួនពិភាក្សាដេញដោលលើ ឯកសារនៅសល់ ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។

៦. សេចក្តីជំទាស់ទាំងនេះត្រូវបានធ្វើឡើង ដើម្បីកុំឲ្យអង្គជំនុំជម្រះគិតពិចារណាទៅលើឯកសារគ្មាន ប្រយោជន៍ច្រើនពេក នៅពេលពិភាក្សាសម្រេច។ យើងខ្ញុំជំទាស់តែទៅលើភាពអាចទទួលយកបាន ប៉ុណ្ណោះ គឺមិនជំទាស់ទៅលើតម្លៃជាភ័ស្តុតាងនោះឡើយ។

## I- ការជំទាស់តាមប្រភេទឯកសារ

៧. មេធាវីការពារក្តីសូមយោងទៅលើទឡ្ហីករណ៍ទាំងអស់ ដែលបានលើកឡើងនៅក្នុងសេចក្តីជំទាស់ ដែលបានដាក់កាលពីខែ វិច្ឆិកា ឆ្នាំ ២០១១[3] ចំពោះចម្លើយសារភាព[4] សៀវភៅ និងខ្សែភាពយន្ត

---

[2] ប្រតិចារឹកសវនាការ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/47.1 ទំព័រ ៤ និង ៥។

[3] សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារដែលដាក់ដោយភាគីផ្សេងទៀតសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង (ពីថ្ងៃទី ២៨ ខែ វិច្ឆិកា ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១) ឯកសារ E131/6 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[4] ដូចយោងខាងលើ កថាខណ្ឌ ១៨ ដល់ ២១។

ឯកសារ[5]។ មេធាវីការពារក្តីសូមជំទាស់ផងដែរទៅលើរបាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ដែលរៀបរាប់ឡើងវិញនូវសម្តីរបស់សាក្សី ដែលត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយ។ តារាងដែលត្រូវបានភ្ជាប់ឧបសម្ព័ន្ធមិនមែនជាការបង្ហាញទឡ្ហីករណ៍ដដែលៗដែលបានលើកឡើងពីមុនរួចមកហើយនោះទេ គឺជាការពន្យល់ជាក់លាក់ចំពោះឯកសារនីមួយៗថាហេតុអ្វីបានជាអង្គជំនុំជម្រះគប្បីប្រកាសមិនទទួលយកឯកសារទាំងនោះ។

## II- ឯកសារចំនួន ៥៦ ដែលកំណត់ដោយក្រុមមេធាវីការពារក្តីលោក អៀង សារី

៨. បន្ថែមពីលើទឡ្ហីករណ៍ផ្ទាល់មាត់ លោក ខៀវ សំផន សូមជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារ D108/31.28។

៩. ឯកសារនេះជាទូរលេខរបស់ ម៉េត ផ្ញើជូន ឌុច។ ឯកសារនេះមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាមិនបានរកឃើញច្បាប់ដើមនោះទេ។ យើងក៏មិនដឹងថាអ្នកណាជាអ្នកបកប្រែនោះដែរ ប៉ុន្តែ ឯកសារនេះមានប្រភពចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ជាការឆ្លើយតបទៅនឹងឯកសារដែលបង្ហាញដោយសហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក ខៀវ សំផន មេធាវីការពារក្តីបានបញ្ជាក់ កាលពីសវនាការថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថា ការបកប្រែរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមិនអាចជឿទុកចិត្តបាន។ សហព្រះរាជអាជ្ញាបានចាត់ទុកឯកសារមួយថាជាសុន្ទរកថារបស់លោក ខៀវ សំផន ដោយផ្អែកលើសំណៅបកប្រែជាភាសាអង់គ្លេសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ គេបកប្រែជាភាសាអង់គ្លេសថាសុន្ទរកថារបស់ "គណៈប្រធានរដ្ឋ" ឯច្បាប់ដើមជាភាសាខ្មែរនិយាយអំពី "ប្រធានគណៈអធិបតី" (E3/165)។ មេធាវីការពារក្តីមានលទ្ធភាពអាចពិនិត្យផ្ទៀងផ្ទាត់ការបកប្រែសុន្ទរកថាដោយមជ្ឈមណ្ឌលឯកសារកម្ពុជានេះបាន ដោយសារតែមានច្បាប់ដើមជាភាសាខ្មែរ។ ចំណែកឯទូរលេខ D108/31.28 មិនមានច្បាប់ដើមសម្រាប់ពិនិត្យផ្ទៀងផ្ទាត់នោះទេ។ អង្គជំនុំជម្រះគប្បីប្រកាសមិនទទួលយកឯកសារនេះ ដោយហេតុថាវាមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង។

១០. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

---

[5] ដូចយោងខាងលើ កថាខណ្ឌ ២៤ ដល់ ៣០ និងកថាខណ្ឌ ៣៥ ដល់ ៣៨។

- **សម្រេច និងប្រកាស** មិនទទួលយកឯកសារ D108/31.28 និងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធនៃសារណានេះ យោងតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Arthur VERCKEN<br>មេធាវី Jacques VERGÈS | ទីក្រុងភ្នំពេញ<br>ទីក្រុងភ្នំពេញ<br>ទីក្រុងប៉ារីស<br>ទីក្រុងប៉ារីស | |